ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការគណៈរដ្ឋមន្ត្រី
អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល
លេខ: ០០៧/២៣ មក.... អអរ

# សេចក្ដីប្រកាសព័ត៌មាន
# ស្ដីពី
# វេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន លើកទី១៩
# ក្រោមការដឹកនាំរបស់ សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត
# នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញដឹកនាំ **វេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន លើកទី១៩** នៅវិមានសន្តិភាព ទីស្ដីការគណៈរដ្ឋមន្ត្រី នាព្រឹកថ្ងៃចន្ទ ១កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៣។ វេទិកានេះ មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំរាជរដ្ឋាភិបាល-ផ្នែកឯកជន សរុបប្រមាណ **១ ២០០នាក់** ក្នុងនោះមកពីក្រុមការងារតាមវិស័យ **ចំនួន១៤** រួមមាន **១**-ក្រុមការងារផ្នែកកសិកម្ម កសិ-ឧស្សាហកម្ម **២**-ក្រុមការងារផ្នែកទេសចរណ៍ **៣**-ក្រុមការងារផ្នែកកម្មន្តសាល សហគ្រាសធុនតូច និងមធ្យម និងសេវា **៤**-ក្រុមការងារផ្នែកនីតិកម្ម ពន្ធដារ និងអភិបាលកិច្ច **៥**-ក្រុមការងារផ្នែកសេវាធនាគារ និងហិរញ្ញវត្ថុ **៦**-ក្រុមការងារផ្នែកដឹកជញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធ **៧**-ក្រុមការងារផ្នែកផលិតកម្មកែច្នៃសម្រាប់នាំចេញ និងកិច្ចសម្រួលពាណិជ្ជកម្ម **៨**-ក្រុមការងារផ្នែកទំនាក់ទំនងវិជ្ជាជីវៈ **៩**-ក្រុមការងារផ្នែកស្រូវ-អង្ករ **១០**-ក្រុមការងារផ្នែកថាមពល និងធនធានរ៉ែ **១១**-ក្រុមការងារផ្នែកអប់រំ **១២**-ក្រុមការងារផ្នែកសុខាភិបាល **១៣**-ក្រុមការងារផ្នែកសំណង់ និងអចលនទ្រព្យ និង**១៤**-ក្រុមការងារផ្នែកសេវាហិរញ្ញវត្ថុមិនមែនធនាគារ។ វេទិកានេះ ក៏មានការអញ្ជើញចូលរួមពីតំណាងអង្គទូតបរទេសនានាប្រចាំនៅកម្ពុជាផងដែរ។

មានប្រសាសន៍បើកវេទិកា នាឱកាសនោះ **សម្ដេចធិបតី** បានគូសបញ្ជាក់ថា **វេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន លើកទី១៩** នាថ្ងៃនេះ ត្រូវបានចាត់ទុកជា **កិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីបើកទូលាយ** ដើម្បីជំរុញសេដ្ឋកិច្ចជាតិដែលពាក់ព័ន្ធផ្ទាល់នឹងជីវភាពប្រជាពលរដ្ឋ ជាសក្ខីភាពនៃកិច្ចសហការស្អិតរមួត និងវប្បធម៌សន្ទនារបស់រាជរដ្ឋាភិបាល និងផ្នែកឯកជន ដើម្បីរួមគ្នាដោះស្រាយបញ្ហាប្រឈម និងកង្វល់របស់ធុរជន ក្នុងគោលដៅជំរុញការអភិវឌ្ឍវិស័យឯកជននៅកម្ពុជា និងជាការអនុវត្តតាមការសន្យាដែល **សម្ដេច** បានថ្លែងក្នុងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី លើកដំបូង កាលពីថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣។ **សម្ដេចធិបតី** គូសបញ្ជាក់ទៀតថា៖ «**វេទិកា**

នេះ ក៏បានបង្ហាញពីភាពបន្ទាន់ និងចាំបាច់នៃរបៀបវារៈសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាលនៅក្នុងអាណត្តិថ្មីនេះ ដែលយើងមានបំណងធ្វើដំណើររួមគ្នារវាងរាជរដ្ឋាភិបាល-ផ្នែកឯកជន តាំងពីដើមអាណត្តិ ឱ្យមានភាពស៊ីចង្វាក់គ្នា និងមានភាពសុខដុមដើម្បីឈានទៅសម្រេចមហិច្ឆតារួមរបស់កម្ពុជា គឺចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០»។ **សម្តេចធិបតី** បានរំលឹកអំពីភាពប៉ិនប្រសប់ប្រកបដោយគតិបណ្ឌិត របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលបានផ្តួចផ្តើមរៀបចំ **វេទិការវាងរាជរដ្ឋាភិបាល-ផ្នែកឯកជន** ជាលើកដំបូង កាលពីឆ្នាំ១៩៩៩ និងជាបន្តបន្ទាប់រហូតដល់ឆ្នាំ២០១៩ ដោយទទួលបានជោគជ័យត្រចះត្រចង់ រួមចំណែកធ្វើឱ្យកម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចជាមធ្យម **៧ភាគរយ** ក្នុងមួយឆ្នាំ ក្នុងរយៈពេលជាង២ទសវត្សរ៍ ប្រែក្លាយកម្ពុជាពីប្រទេសក្រីក្រ ឱ្យទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាបនៅឆ្នាំ២០១៥ ទាញប្រជាជនកម្ពុជារាប់លាននាក់ឱ្យចាកផុតពីភាពក្រីក្រ។

ក្នុងកិច្ចដំណើរការនៃ **វេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន លើកទី១៩** នោះ អង្គវេទិកាបានស្តាប់ របាយការណ៍ស្តីពី ការរៀបចំយន្តការសម្របសម្រួល និងវឌ្ឍនភាពទូទៅនៃក្រុមការងារទាំង**១៤** ដែលថ្លែងដោយ **ឯកឧត្តម ស៊ុន ចាន់ថុល** ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងជាប្រធានគណៈកម្មាធិការសម្របសម្រួលការងារសម្រាប់យន្តការវេទិការាជរដ្ឋាភិបាល-វិស័យឯកជន របាយការណ៍អំពីលទ្ធផលសង្ខេប នៃកិច្ចពិភាក្សាទាំងឡាយរបស់ក្រុមការងារតាមវិស័យ ថ្លែងដោយ **អ្នកឧកញ៉ា គិត ម៉េង** ប្រធានសភាពាណិជ្ជកម្មកម្ពុជា ក្នុងនាមប្រធានសម្របសម្រួលរួមរបស់ផ្នែកឯកជន បទអន្តរាគមន៍ពីបញ្ហាប្រឈមរបស់វិស័យឯកជន ថ្លែងដោយ **ឧកញ៉ា លូ ម៉េង** តំណាងក្រុមការងារផ្នែកទេសចរណ៍ **ឧកញ៉ា សូ ងួន** តំណាងក្រុមការងារផ្នែកដឹកជញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធ **ឧកញ៉ាបណ្ឌិត ណាង សុធី** តំណាងក្រុមការងារផ្នែកទំនាក់ទំនងវិជ្ជាជីវៈ។ បន្ទាប់មក **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានថ្លែងរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអភិវឌ្ឍន៍វិស័យឯកជន និងការដោះស្រាយបញ្ហាដែលមានចរិតលក្ខណៈជាប្រព័ន្ធ និងជារចនាសម្ព័ន្ធ នៃការកែទម្រង់ពាក់ព័ន្ធនឹងគោលនយោបាយ ឬអន្តរវិស័យ។ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ឱ្យដឹងថា រាជរដ្ឋាភិបាលបានទទួលសំណូមពរ និងអនុសាសន៍ពីវិស័យឯកជនសរុប **ចំនួន១៨៦** ដោយសរុបជាបញ្ហារួម មានចំនួន១០ចំណុចសំខាន់ៗ ដើម្បីដាក់គោរពជូន **សម្តេចធិបតី** ពិនិត្យ និងសម្រេច។

ក្រោយពីបានស្តាប់របាយការណ៍ និងបទអន្តរាគមន៍ជាបន្តបន្ទាប់រួចមក **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានសម្រេចដាក់ចេញនូវដំណោះស្រាយយ៉ាងច្បាស់លាស់ ធ្វើឱ្យអង្គវេទិកាទាំងមូលមានអំណរសាទរយ៉ាងក្រៃលែង ជាពិសេសការឆ្លើយតបដ៏ខ្ពង់ខ្ពស់របស់ **សម្តេចធិបតី** លើសំណូមពរគោលសំខាន់ៗទាំង១០ ដូចខាងក្រោម៖

**ទី១**-ការសម្រួលបរិយាកាសធុរកិច្ច និងការវិនិយោគ តាមរយៈការផ្តល់ការសម្របសម្រួលក្នុងការបំពេញកាតព្វកិច្ចគណនេយ្យនិងសវនកម្ម ការលើកកម្ពស់តម្លាភាព នៃការងារប្រយុទ្ធប្រឆាំងនឹងផលិតផលក្លែងក្លាយ ការបន្តជំរុញការរៀបចំចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ការគាំទ្របន្ថែមដល់សហគ្រាសធុនមីក្រូ តូច និងមធ្យម និងការចូលរួមរបស់វិស័យឯកជនក្នុងរៀបចំបទដ្ឋានគតិយុត្ត។

ទី២-ការសម្រាលបន្ទុកលើអនុលោមភាព តាមរយៈការជំរុញការអនុវត្តយន្តការក្រុមការងារអធិការកិច្ចអន្តរក្រសួង ការបន្តជំរុញការអនុវត្តជំនាញ និងផលិតភាពរបស់កម្មករនិយោជិត និងការពង្រឹងការដោះស្រាយវិវាទការងារក្រៅប្រព័ន្ធតុលាការ។

ទី៣-ការសម្រួលធុរកិច្ចនៅក្រោមដែនសមត្ថកិច្ចពន្ធដារ តាមរយៈការបន្តគោលនយោបាយមិនយកពន្ធ ការលុបការបង់ភាស៊ី និងការបង់កម្រៃផ្សេងៗ ការអនុគ្រោះបន្ថែមពាក់ព័ន្ធនឹងពន្ធលើអចលនទ្រព្យ ការកែសម្រួលការប្រមូលពន្ធលើដីធ្លីមិនប្រើប្រាស់ ការសម្រួលនិងការពង្រីកវិសាលភាពនៃការអនុគ្រោះពន្ធក្នុងវិស័យកសិកម្ម ការផ្តល់ការអនុគ្រោះពិសេសនៅក្នុងវិស័យទេសចរណ៍ក្នុងខេត្តសៀមរាប ការលើកទឹកចិត្តផ្សេងទៀត និងការបន្តជំរុញកិច្ចការកែទម្រង់រដ្ឋបាលសារពើពន្ធ។

ទី៤-ការលើកកម្ពស់កិច្ចសម្រួលពាណិជ្ជកម្មនៅក្រោមដែនសមត្ថកិច្ចគយ តាមរយៈវិធានការសម្រួលវិធាន និងនីតិវិធីក្នុងការបញ្ចេញទំនិញ ការលើកកម្ពស់ប្រសិទ្ធភាពសេវាគយ និងការបន្តជំរុញការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិកឱ្យកាន់តែច្រើន ការអនុញ្ញាតឱ្យមានការផ្តល់សេវាធ្វើការបន្ថែមម៉ោងរបស់មន្ត្រីគយនៅពេលយប់ ការបន្តជំរុញការបណ្តុះបណ្តាល និងផ្តល់អាជ្ញាបណ្ណជើងសារគយ និងការពង្រឹងការគ្រប់គ្រងលើការនាំចូលដោយខុសច្បាប់នូវសាច់ជ្រូកបង្កក មាន់ ស៊ុត និងត្រីជាដើម។

ទី៥-ការលើកកម្ពស់ការដឹកជញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធតាមរយៈការតម្លើងកម្រិតទំងន់រថយន្តដឹកទំនិញ។

ទី៦-ការស្តារ និងការលើកស្ទួយការអភិវឌ្ឍវិស័យទេសចរណ៍ តាមរយៈការដាក់ឱ្យដំណើរការក្រុមប្រឹក្សាទេសចរណ៍ដើម្បីលើកកម្ពស់កិត្តិនាមកម្ពុជា ការសម្រួលដល់ទេសចរណ៍ក្នុងការទស្សនាខេត្តសៀមរាបដោយផ្សារភ្ជាប់ទៅនឹងការតភ្ជាប់ជើងហោះហើរ និងការកែសម្រួលទិដ្ឋាការ ការលើកកម្ពស់បដិសណ្ឋារកិច្ចតាមច្រកទ្វារព្រំដែន ការគិតគូរពង្រីកវិសាលភាពបណ្ណព្រំដែន និងការផ្តល់ហិរញ្ញប្បទានដល់ប្រតិបត្តិករទេសចរណ៍ខេត្តសៀមរាប ព្រមទាំងការលើកទឹកចិត្តផ្នែកពន្ធដារនៅក្នុងវិស័យនេះ។

ទី៧-ការជំរុញការអភិវឌ្ឍវិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម តាមរយៈការកសាងប្រព័ន្ធផលិតពូជសុទ្ធលើប្រភេទស្រូវផ្ការំដួល និងសែនក្រអូប ការពង្រឹងគុណភាពនៃការនាំចូលគ្រាប់ពូជបន្លែ និងការផលិតពូជបន្លែក្នុងស្រុក ការជំរុញការនាំចេញអង្ករ និងគ្រាប់ស្វាយចន្ទី ការរៀបចំសហគមន៍កសិកម្ម ការរៀបចំបង្កើតច្បាប់ស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា និងការអនុវត្តយន្តការលើកទឹកចិត្ត។

ទី៨-ការជំរុញការចូលរួមចំណែករបស់វិស័យធនាគារ ដើម្បីបង្កើនលទ្ធភាពទទួលបានឥណទានសម្រាប់វិស័យឯកជន ដោយរក្សាបាននូវស្ថិរភាពហិរញ្ញវត្ថុ តាមរយៈការរក្សាអនុបាតទ្រនាប់ដើមទុនដែលមានភាពអនុគ្រោះ ការអនុញ្ញាតឱ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុបន្តអនុវត្តប្រាក់បម្រុងកាតព្វកិច្ចជារូបិយបណ្ណក្នុងកម្រិតសមស្រប និងការបន្តលើកទឹកចិត្តគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុឱ្យរៀបចំឥណទានឡើងវិញ។

ទី៩-ការជំរុញការអភិវឌ្ឍវិស័យរ៉ែ និងថាមពល តាមរយៈការកែលម្អការគ្រប់គ្រង និងការជំរុញលើកទឹកចិត្តការធ្វើអាជីវកម្មការនាំចេញថ្មអារ ការធ្វើសាមញ្ញកម្មនីតិវិធីនៃការចេញវិញ្ញាបនបត្របញ្ជាក់ការនាំចេញ ការបន្តជំរុញការប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យលើដំបូល។

ទី១០-ការគាំទ្រដល់វិស័យសំណង់ និងអចលនទ្រព្យ តាមរយៈការបន្តអនុវត្តវិធានការដាកព្វាប់រួមមាន បន្តពន្យារពេលការអនុវត្ត និងការបង្កើនរយៈពេលនៃការបង់ពន្ធជាកញ្ចប់តាមដំណាក់កាល ការលើកទឹក

ចិត្តផ្នែកសារពើពន្ធ និងការលើកលែងការផាកពិន័យនានា ការបន្ធូរបន្ថយកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យវងសវនកម្មឯករាជ្យ ព្រមទាំងការផ្តល់សិទ្ធិឱ្យជនបរទេសអាចកាន់កាប់អចលនទ្រព្យជាដើម។

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក៏បានថ្លែងអំណរគុណចំពោះតំណាងផ្នែកឯកជនទាំងអស់ ដែលចូលរួមចំណែកអភិវឌ្ឍន៍ប្រទេសកម្ពុជាជាមួយរាជរដ្ឋាភិបាល។ **សម្តេចធិបតី** បានស្វាគមន៍ចំពោះការលើកឡើងដោយស្មោះត្រង់ និងក្នុងន័យស្ថាបនាពាក់ព័ន្ធនឹងបញ្ហាប្រឈមនានា ក្នុងនាមជាដៃគូសន្ទនាដែលមិនអាចខ្វះបាន និងបានបំពេញឱ្យគ្នាទៅវិញទៅមក ក្នុងដំណើរឆ្ពោះទៅកាន់សមាហរណកម្មសកលឱ្យកាន់តែទូលំទូលាយក្នុងវិស័យធុរកិច្ច។ ជាមួយគ្នានោះដែរ **សម្តេចធិបតី** បានណែនាំឱ្យបង្កើតក្រុមការងារផ្នែកសេដ្ឋកិច្ច និងសង្គមឌីជីថល បន្ថែមលើក្រុមការងារតាមវិស័យដែលមានស្រាប់ចំនួន១៤ ដើម្បីឆ្លើយតបនឹងយុទ្ធសាស្ត្របញ្ចកោណ។

សូមបញ្ជាក់ថា **វេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន** បានខកខានរៀបចំរយៈពេល៤ឆ្នាំ ក្រោយមានការរាតត្បាតដោយជំងឺកូវីដ-១៩។ យន្តការនេះត្រូវបានធនាគារពិភពលោកទទួលស្គាល់ថា ជាកិច្ចសន្ទនារវាងរដ្ឋ និងឯកជនដែលមានប្រសិទ្ធភាពខ្ពស់ និងមានសមិទ្ធផលយ៉ាងធំធេង។ ទោះបីជានៅក្នុងនីតិកាលទី៦ នៃរដ្ឋសភា កម្ពុជា និងបណ្តាប្រទេសផ្សេងទៀត បានរងសម្ពាធយ៉ាងធ្ងន់ធ្ងរពីបញ្ហាប្រឈមសកលជាបន្តបន្ទាប់ រួមមាន ការឆ្លងរាលដាលជំងឺកូវីដ-១៩ ការប្រែប្រួលអាកាសធាតុ សង្គ្រាមពាណិជ្ជកម្ម ភាពតានតឹងផ្នែកភូមិសាស្ត្រនយោបាយ សង្គ្រាមអ៊ុយក្រែន-រុស្ស៊ី វិបត្តិថាមពល និងការរឹតបន្តឹងគោលនយោបាយរូបិយវត្ថុជាដើម ក៏រាជរដ្ឋាភិបាលកម្ពុជា នៅតែអាចសម្រេចបាននូវសមិទ្ធផលដ៏ធំធេងជាច្រើន មានជាអាទិ៍ ការគ្រប់គ្រងដោយជោគជ័យ និងការយកឈ្នះលើសមរភូមិប្រយុទ្ធនឹងជំងឺកូវីដ-១៩ ការស្តារនិងជំរុញនូវកំណើនសេដ្ឋកិច្ចឡើងវិញ ការធ្វើជាម្ចាស់ផ្ទះកិច្ចប្រជុំកំពូលអាស៊ានលើកទី៤០ និង៤១ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ការធ្វើជាម្ចាស់ផ្ទះរៀបចំកីឡាអាស៊ីអាគ្នេយ៍លើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេមលើកទី១២ និងការរៀបចំការបោះឆ្នោតឃុំ សង្កាត់ ឆ្នាំ២០២២ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ២០២៣៕

ថ្ងៃចន្ទ ១កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៣

**អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល**